**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ១៤៥/១៥ ក.អ.ជ.សរ

ថ្ងៃអង្គារ ១៥កើត ខែបឋមាសាឍ ឆ្នាំមមែ ព.ស.២៥៥៩

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមិថុនា គ.ស. ២០១៥

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារសម្របសម្រួល និងអនុវត្តគម្រោង សាកល្បងផ្ទេរមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទទៅរដ្ឋបាលស្រុក

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៨ ស្តីពីការបង្កើត គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

អាសយដ្ឋាន [illegible] 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញសេចក្តីសម្រេច លេខ ១០៣ សសរ/គ.ជ.អ.ប ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៤ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងប្រកាសលេខ ០៤៣/១៥ កអជប្រក ចុះថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ ២០១៥ របស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ស្តីពីការផ្ទេរប្រតិភូកម្មមុខងារផ្គូសផ្គុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទជូនរដ្ឋបាលស្រុកឈូក ស្រុកជុំគីរី ស្រុកបន្ទាយមាស និងស្រុកកំពង់ត្រាចនៃខេត្តកំពត និងស្រុកមេមត់ស្រុកត្បូងឃ្មុំ និងស្រុកក្រូចឆ្មារ នៃខេត្តត្បូងឃ្មុំ
- យោងលិខិតរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ៣៧២៣ សហវ.អហក ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៥
- យោងលិខិតរបស់ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប លេខ ៣៥០ សណ/គ.ជ.អ.ប ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១៥

## **សម្រេច**

**ប្រការ ១.-**

តែងតាំងសមាសភាពក្រុមការងារសម្របសម្រួល និងអនុវត្តគម្រោងសាកល្បងផ្ទេរមុខងារផ្គូសផ្គុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទទៅរដ្ឋបាលស្រុក ដែលមានដូចខាងក្រោម÷

| | | |
|---|---|---|
| ១- | លោកបណ្ឌិត **យ៉ាន់ ម៉ាន់ដឺលុច** អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ កអជ | ប្រធាន |
| ២- | លោក**សុខ សុទ្ធី** អនុប្រធានអង្គភាពវិភាគនិងអភិវឌ្ឍន៍គោលនយោបាយ លេខាធិការដ្ឋាន គ.ជ.អ.ប | អនុប្រធាន |
| ៣- | លោក **ម៉ៅ សារ៉ាយ** ប្រធាននា.ផ្គត់ផ្គង់ទឹកជនបទនៃក.អ.ជ. | អនុប្រធាន |
| ៤- | លោក **ឡុន ពេជ្រនិមិត្ត** អនុប្រធាននា.ផ្គត់ផ្គង់ទឹកជនបទនៃក.អ.ជ. | សមាជិកអចិន្ត្រៃយ៍ |
| ៥- | លោក **ឃុ ចំណាន** អនុប្រធាននា.ផ្គត់ផ្គង់និងហិរញ្ញវត្ថុនៃក.អ.ជ. | សមាជិក |
| ៦- | លោក **សុក សុផល្លី** អនុប្រធាននា.ផ្គត់ផ្គង់ទឹកជនបទនៃក.អ.ជ. | សមាជិក |
| ៧- | លោក **សឿន ចន្ថារ៉ា** ប្រធានការិ.នៃអគ្គ.ហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិនៃក្រ.ស.ហ.វ. | សមាជិក |
| ៨- | កញ្ញា **គង់ ម៉ុណ្ណា** ប្រធានមុខងាររដ្ឋបាលថ្នាក់ក្រោមជាតិនៃអង្គភាពវិភាគមុខងារ នៃគ.ជ.អ.ប | សមាជិកា |

**ប្រការ ២.-**

ក្រុមការងារសម្របសម្រួល និងអនុវត្តគម្រោងសាកល្បងផ្ទេរមុខងារផ្គូសផ្គុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទទៅរដ្ឋបាលស្រុក មានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- សម្របសម្រួលជាមួយគ្រប់ភាគីពាក់ព័ន្ធ ដើម្បីអនុវត្តគម្រោងសាកល្បងផ្ទេរមុខងារផ្គូសផ្គុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទទៅរដ្ឋបាលស្រុកគោលដៅឱ្យបានសម្រេចជោគជ័យ

- ផ្តល់ការគាំទ្រផ្នែករដ្ឋបាល និងការគាំទ្រដទៃទៀត ដូចជាតម្រូវការឯកសារ លិខិតបទដ្ឋានពាក់ព័ន្ធនានា ដល់ភាគីពាក់ព័ន្ធនឹងការអនុវត្តគម្រោងសាកល្បង
- រៀបចំសេចក្តីព្រាងសេចក្តីណែនាំលម្អិតស្តីពីការគ្រប់គ្រងមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ទៅឱ្យរដ្ឋបាលស្រុកគោលដៅ
- វិភាគ និងកំណត់តួនាទីរបស់អ្នកពាក់ព័ន្ធ ដែលត្រូវអនុវត្តឱ្យបានសមស្រប សម្រាប់បំពេញមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ក្នុងដំណាក់កាលសាកល្បងផ្ទេរមុខងារ
- រៀបចំឯកសារបរិយាយពីតួនាទី និងភារកិច្ច (TOR) របស់អ្នកពាក់ព័ន្ធនានា ដើម្បីធានាថា ការបំពេញមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ក្នុងដំណាក់សាកល្បងផ្ទេរមុខងារនឹងទទួលបានជោគជ័យ
- កំណត់ធនធាន និងប្រភពធនធានចាំបាច់ក្នុងការបំពេញមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ឱ្យមានប្រសិទ្ធភាព
- ណែនាំស្តីពីការផ្ទេរផ្គងការងារ និងធនធាន តាមរយៈការជួយសម្របសម្រួលដល់ការរៀបចំផែនការសកម្មភាព និងថវិកា សម្រាប់បំពេញមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទរបស់រដ្ឋបាលស្រុក និងឃុំគោលដៅ សម្រាប់រយៈពេលសាកល្បង
- ពិភាក្សា ពិនិត្យ និងស្វែងរកដំណោះស្រាយសម្រាប់ការអនុវត្តគម្រោងសាកល្បងផ្ទេរមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទទៅរដ្ឋបាលស្រុក
- រាយការណ៍អំពីដំណើរការនៃការអនុវត្តគម្រោងសាកល្បង ជូនក្រសួងជ្រាបជាប្រចាំ
- ទទួលអនុវត្តភារកិច្ចដទៃទៀតដែលក្រសួងប្រគល់ជូន។

**ប្រការ ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៤.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តគោលដៅ រដ្ឋបាលស្រុកគោលដៅ និងសាមីខ្លួនដែលមានចែងក្នុងប្រការ ១ ត្រូវទទួលអនុវត្តសេចក្តីប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

<u>កន្លែងទទួល÷</u>

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- សាលាខេត្ត និង សាលាស្រុកគោលដៅ

"*<u>ដើម្បីជូនជ្រាប</u>*"

- ដូចប្រការ ៤
- ឯកសារ កាលប្បវត្តិ

ជា សុផារ៉ា